**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
លេខ [illegible].សហវ.[illegible]

ថ្ងៃចន្ទ ១៥កើត ខែបឋមាសាឍ ឆ្នាំ ថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែកក្កដា ឆ្នាំ ២០២៣

**ជម្រាបជូន**
**ឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**កម្មវត្ថុ:** គោលការណ៍នៃការអនុវត្តចំណាយថវិកាក្រសួងអប់រំ យុវជន និងកីឡាសម្រាប់គាំទ្រដល់ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ។
**យោង:** លិខិតលេខ ២៩៩ អយក.ហវ ចុះថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០២៣ របស់ក្រសួងអប់រំ យុវជន និងកីឡា។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូន **ឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី** ជ្រាបថា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានពិនិត្យនិងឯកភាពជាគោលការណ៍លើចំណាយថវិកាក្រសួងអប់រំ យុវជន និងកីឡាសម្រាប់គាំទ្រដល់ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ដែលត្រូវអនុវត្តចាប់ពីឆ្នាំ ២០២៣ តទៅ ដូចខាងក្រោម÷

## I. ការរៀបចំថវិកា

មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ត្រូវគ្រោងថវិកាសម្រាប់គាំទ្រដល់ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ក្នុងក្របខ័ណ្ឌវិស័យអប់រំ យុវជន និងកីឡា ក្នុងអនុគណនី ៦២០២៨ "ជំនួយសង្គមផ្សេងៗទៀត" ចំនួន ៣០ លានរៀល ក្នុង ១ ឆ្នាំ សម្រាប់ ១ ការិយាល័យ។ ថវិកាសម្រាប់គាំទ្រដល់ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ មានមុខសញ្ញាចំណាយដូចខាងក្រោម÷

ក. សោហ៊ុយបេសកកម្មក្នុងប្រទេស

ជូនមន្ត្រីការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ក្នុងការចូលរួមកិច្ចប្រជុំ សន្និសីទ សន្និបាត វគ្គសិក្ខាសាលា វគ្គបណ្តុះបណ្តាល និងកម្មវិធីផ្សេងៗ ដែលរៀបចំដោយក្រសួង/មន្ទីរអប់រំ យុវជន និងកីឡា ក្នុងគោលដៅដើម្បីចូលរួមចំណែកសម្រេចគោលបំណងគោលនយោបាយវិស័យអប់រំ យុវជន និងកីឡា។

ខ. សម្ភារសម្រាប់ការងាររដ្ឋបាល

ជូនការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុកខណ្ឌ ដើម្បីគាំទ្រដល់ការអនុវត្តសកម្មភាពក្នុងវិស័យអប់រំ យុវជន និងកីឡា។

ថវិកានេះ មិនត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់សម្រាប់មុខសញ្ញាចំណាយផ្សេងទៀតឡើយ។ មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ត្រូវសម្របសម្រួល និងចាត់ចែងចំណាយថវិកាលើមុខសញ្ញាខាងលើឱ្យបានហ្មត់ចត់ ដើម្បីធានានូវនិរន្តរភាព និងប្រសិទ្ធភាពការងារ រហូតដល់ដំណាច់ឆ្នាំ។

## II. **នីតិវិធីនៃការអនុវត្តថវិកា**

ការអនុវត្តចំណាយថវិកាសម្រាប់គាំទ្រដល់ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវអនុវត្តតាមនីតិវិធីបើកផ្តល់សាច់ប្រាក់មុន។ មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ត្រូវរៀបចំគម្រោងចំណាយនេះ សម្រាប់អនុវត្តតាមនីតិវិធីបើកផ្តល់សាច់ប្រាក់មុន តាមរយៈរដ្ឋទេយ្យករបុរេប្រទាននៃមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត។

ការអនុវត្តចំណាយតាមនីតិវិធីបើកផ្តល់សាច់ប្រាក់មុនខាងលើ ត្រូវអនុលោមតាមយន្តការជុំបង្វិល និងការបំពេញបេឡាឡើងវិញ ដោយត្រូវធ្វើឡើងតាមគោលការណ៍ដូចខាងក្រោម÷

- នៅមុនដំណាច់ខែវិច្ឆិកា មុនឆ្នាំអនុវត្តថវិកា, មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ត្រូវរៀបចំគម្រោងចំណាយថវិកាតាមនីតិវិធីបើកផ្តល់សាច់ប្រាក់មុន សម្រាប់សោហ៊ុយបេសកកម្មក្នុងប្រទេស និងសម្ភារសម្រាប់ការងាររដ្ឋបាលរបស់ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងរៀបចំលិខិតស្នើសុំបើកប្រាក់លើកដំបូង ក្នុងកម្រិតទឹកប្រាក់ ១/២ នៃឥណទានថវិកាសរុបសម្រាប់អនុវត្តតាមនីតិវិធីបើកផ្តល់សាច់ប្រាក់មុន រួចបញ្ជូនមកអ្នកត្រួតពិនិត្យថវិកានៃមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត និងគណនេយ្យករសាធារណៈនៃរតនាគាររាជធានី ខេត្ត ដោយត្រូវភ្ជាប់នូវសំណើ និងគម្រោងចំណាយ ដូចមានគំរូភ្ជាប់ជាឧបសម្ព័ន្ធនៃគោលការណ៍នេះ។

  *ដោយឡែកសម្រាប់ឆ្នាំ ២០២៣, មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ត្រូវបានអនុញ្ញាតឱ្យរៀបចំគម្រោងចំណាយថវិកាតាមនីតិវិធីបើកផ្តល់សាច់ប្រាក់មុន សម្រាប់សោហ៊ុយបេសកកម្មក្នុងប្រទេស និងសម្ភារសម្រាប់ការងាររដ្ឋបាលរបស់ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងរៀបចំលិខិតស្នើសុំបើកប្រាក់លើកដំបូង ក្នុងកម្រិតទឹកប្រាក់ ១/២ នៃឥណទានថវិកាសរុបសម្រាប់អនុវត្តតាមនីតិវិធីបើកផ្តល់សាច់ប្រាក់មុន ក្រោយទទួលបានគោលការណ៍អនុវត្តចំណាយថវិកានេះ។*

- រដ្ឋទេយ្យករបុរេប្រទាននៃមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ត្រូវចាត់ចែងនូវសាច់ប្រាក់ដែលខ្លួនបានទទួលពីរតនាគាររាជធានី ខេត្ត ជូនការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ព្រមទាំងទុកដាក់ថែរក្សាលិខិតយុត្តិការ និងកាន់កាប់បញ្ជីបេឡាដោយឡែក សម្រាប់តាមដានចំណូល ចំណាយ និងសាច់ប្រាក់ដែលនៅសល់ សម្រាប់គាំទ្រដល់ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ។
- ក្រោយទទួលបានសាច់ប្រាក់ពីរដ្ឋទេយ្យករបុរេប្រទាននៃមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត, ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវចាត់ចែងប្រើប្រាស់

សម្រាប់តែមុខសញ្ញាចំណាយដែលមានចែងក្នុងចំណុច (I) ខាងលើ ដោយផ្អែកលើមូលដ្ឋានដូចខាងក្រោម÷

- សម្រាប់ចំណាយប្រាក់បេសកកម្មក្នុងប្រទេសរបស់មន្ត្រីការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវមានលិខិតបញ្ជាបេសកកម្ម ទិដ្ឋាការធ្វើដំណើរពីរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងវិក្កយបត្រធ្វើដំណើរក្នុងករណីមិនប្រើប្រាស់មធ្យោបាយធ្វើដំណើររបស់រដ្ឋ ឬផ្ទាល់ខ្លួន សម្រាប់ចូលរួមកិច្ចប្រជុំ សន្និសីទ សន្និបាត វគ្គសិក្ខាសាលា វគ្គបណ្តុះបណ្តាល និងកម្មវិធីផ្សេងៗ ដែលរៀបចំដោយក្រសួង/មន្ទីរអប់រំ យុវជន និងកីឡា។ គោលរបបនៃសោហ៊ុយបេសកកម្មក្នុងប្រទេស ត្រូវអនុលោមតាមអនុក្រឹត្យលេខ ០៦ អនក្រ.បក ចុះថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០២១ ស្តីពីប្រាក់បេសកកម្មនៅក្នុងនិងក្រៅប្រទេសសម្រាប់រដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងប្រកាសលេខ ០៩៩ សហវ.ប្រក ចុះថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០២១ ស្តីពីវិធាននិងនីតិវិធីចំណាយប្រាក់បេសកកម្មនៅក្នុងនិងក្រៅប្រទេសសម្រាប់រដ្ឋបាលថ្នាក់ជាតិ។
- សម្រាប់ចំណាយលើសម្ភារសម្រាប់ការងាររដ្ឋបាល ត្រូវមានការបញ្ជាក់ទទួលស្គាល់លើសក្ខីបត្រចំណាយដោយប្រធានការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ។

➢ ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវរៀបចំរបាយការណ៍ចំណាយឱ្យបានរួសរាន់ និងត្រូវប្រគល់ជូនរដ្ឋទេយ្យករបុរេប្រទាននៃមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត។

➢ រដ្ឋទេយ្យករបុរេប្រទាននៃមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ត្រូវរៀបចំបោះផ្សាយអាណត្តិនិយតកម្មទូទាត់ជម្រះបញ្ជី ឬ/និងបំពេញបេឡាឡើងវិញ ឱ្យបានត្រឹមត្រូវ និងឆាប់រហ័សដោយមិនត្រូវរង់ចាំរហូតដល់អស់សាច់ប្រាក់ពីបេឡានោះឡើយ ដើម្បីធានាដល់ការអនុវត្តសកម្មភាពគាំទ្រដល់ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ឱ្យបានទាន់ពេលវេលា។

➢ ក្នុងដំណាក់កាលអន្តរកាល នៅពេលមុខងារស្កេនលិខិតយុត្តិការចំណាយពុំទាន់អាចអនុវត្តក្នុងប្រព័ន្ធ FMIS បាននៅឡើយ មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត តម្រូវឱ្យភ្ជាប់តែរបាយការណ៍ចំណាយទៅតាមមុខសញ្ញាចំណាយនីមួយៗ ឱ្យបានច្បាស់លាស់ តាមគំរូភ្ជាប់ជាឧបសម្ព័ន្ធនៃគោលការណ៍នេះ ជាមួយអាណត្តិនិយតកម្ម/អាណត្តិបើកប្រាក់ មកមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរតនាគាររាជធានី ខេត្ត ដោយរក្សាទុកសក្ខីប័ត្រដើមនៅមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត សម្រាប់ជាកម្មវត្ថុនៃការធ្វើសវនកម្ម ឬធ្វើអធិការកិច្ចតាមក្រោយជាយថាហេតុ។

➢ នៅពេលមុខងារស្កេនលិខិតយុត្តិការចំណាយ អាចអនុវត្តបានក្នុងប្រព័ន្ធ FMIS, លិខិតយុត្តិការចំណាយដែលជាច្បាប់ដើម ត្រូវរក្សាទុកនៅមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត និងត្រូវស្កេនបញ្ចូលទៅក្នុងប្រព័ន្ធ FMIS ដើម្បីជាមូលដ្ឋានក្នុងការពិនិត្យដោយអ្នកត្រួតពិនិត្យ

ថវិកានៃមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត និងគណនេយ្យករសាធារណៈនៃរតនាគាររាជធានី ខេត្ត និងសម្រាប់ជាកម្មវត្ថុនៃការធ្វើសវនកម្ម ឬធ្វើអធិការកិច្ច តាមក្រោយ។

- ការបើកផ្តល់សាច់ប្រាក់មុន បន្ទាប់ទៀត ត្រូវធ្វើឡើងក្រោមរូបភាពជាការបំពេញបេឡាឡើងវិញនូវថវិកាដែលបានចំណាយជាក់ស្តែង ទៅតាមទំហំទឹកប្រាក់ដែលមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត បានបោះផ្សាយអាណត្តិនិយតកម្មស្នើសុំទូទាត់ លើកលែងតែពេលជិតដំណាច់ឆ្នាំដែលត្រូវទូទាត់ជម្រះបញ្ជី ដោយផ្អែកតាមសារាចរណែនាំស្តីពីការបិទបញ្ជីចំណូល ចំណាយថវិកាប្រចាំឆ្នាំរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ទឹកប្រាក់សរុប ដែលបានទូទាត់ និងដែលត្រូវទូទាត់ជម្រះចំណាយ ត្រូវមានទំហំមិនឱ្យលើសពីឥណទានថវិកាសរុបប្រចាំឆ្នាំនៃខ្ទង់ចំណាយនោះទេ។
- នាដំណាច់ឆ្នាំថវិកា ក្នុងករណីមានប្រាក់ដែលអនុវត្តនីតិវិធីបើកផ្តល់សាច់ប្រាក់មុននៅសល់, រដ្ឋទេយ្យករបុរេប្រទាននៃមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ត្រូវយកប្រាក់ដែលនៅសល់នោះមកបង់ចូលគណនីចរន្តរបស់រតនាគាររាជធានី ខេត្ត នៅធនាគារ ឱ្យបានមុនដំណាច់ឆ្នាំថវិកា ដោយត្រូវរៀបចំសំណើបង់សាច់ប្រាក់សល់ពីការបើកផ្តល់មុន ដោយបញ្ជាក់ខ្លឹមសារច្បាស់លាស់អំពីការទូទាត់ជម្រះចំណាយ និងភ្ជាប់មកជាមួយនូវប្រកាសឥណទាន ឬ ប័ណ្ណបង់ប្រាក់ ឬរបាយការណ៍ធនាគារ ដើម្បីមានមូលដ្ឋានចុះកិច្ចបញ្ជិកាជម្រះបញ្ជី។ ក្នុងករណីមិនទាន់មានការបង់សាច់ប្រាក់នៅសល់ និងមិនទាន់មានការបោះផ្សាយអាណត្តិនិយតកម្មទូទាត់ឱ្យបានទាន់នាដំណាច់ឆ្នាំអនុវត្តថវិកា រតនាគាររាជធានី ខេត្ត នឹងមិនបើកផ្តល់សាច់ប្រាក់សម្រាប់គម្រោងចំណាយឆ្នាំបន្ទាប់ជូនមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត នោះទេ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី** មេត្តាជ្រាប និងចាត់ចែងតាមការគួរ។

សូម **ឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី** ទទួលនូវគារវកិច្ចពីខ្ញុំ

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**ចម្លងជូនៈ**
-អគ្គនាយកដ្ឋានរតនាគារជាតិ
-គ្រប់មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត
-គ្រប់រតនាគាររាជធានី ខេត្ត
-គ្រប់មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត
-គ្រប់រដ្ឋបាលក្រុង ស្រុក ខណ្ឌ
“ដើម្បីអនុវត្ត”
-ឯកសារ-កាលប្បវត្តិ

## ឧបសម្ព័ន្ធទី ១

(ឧបសម្ព័ន្ធភ្ជាប់លិខិតលេខ............ សហវ.......... ចុះថ្ងៃទី........... ខែ.......... ឆ្នាំ ២០២៣ ស្តីពីគោលការណ៍នៃការអនុវត្តចំណាយថវិកាសម្រាប់គាំទ្រដល់ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ)

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**

**មន្ទីរអប់រំ យុវជន និងកីឡារាជធានី/ខេត្ត..........**

### គម្រោងចំណាយថវិកាសម្រាប់គាំទ្រដល់ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ សម្រាប់ឆ្នាំ...........
### របស់មន្ទីរអប់រំ យុវជន និងកីឡារាជធានី/ខេត្ត...........

| ជំពូក | គណនី | អនុគណនី | បរិយាយ | ច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ...... | ឥណទានថវិកាបើកផ្តល់សាច់ប្រាក់មុន | ឥណទានថវិកាបើកផ្តល់សាច់ប្រាក់មុនលើកដំបូង |
|---|---|---|---|---|---|---|
| | | | | ១ | ២ =១ | ៣= ២* ៥០% |
| សរុប | | | | | | |
| កម្មវិធីទី.... អនុកម្មវិធីទី.... ចង្កោមសកម្មភាពទី.... សកម្មភាពទី..... | | | | | | |
| ៦២ | ៦២០២ | ៦២០២៨ | ជំនួយសង្គមផ្សេងៗទៀត | | | |

បានឃើញនិងពិនិត្យត្រឹមត្រូវ
ថ្ងៃ.... ខែ.... ឆ្នាំ.... ព.ស.
ថ្ងៃទី... ខែ..... ឆ្នាំ....
ប្រធានរតនាគាររាជធានី ខេត្ត....

បានឃើញនិងពិនិត្យត្រឹមត្រូវ
ថ្ងៃ... ខែ.... ឆ្នាំ..... ព.ស.
ថ្ងៃទី... ខែ..... ឆ្នាំ.....
ប្រធានមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
រាជធានី ខេត្ត....

បានឃើញនិងពិនិត្យត្រឹមត្រូវ
ថ្ងៃ....... ខែ....... ឆ្នាំ........ ព.ស.
ថ្ងៃទី...... ខែ..... ឆ្នាំ........
ប្រធានមន្ទីរអប់រំ យុវជន និងកីឡា
រាជធានី ខេត្ត....

ថ្ងៃ....... ខែ....... ឆ្នាំ........ ព.ស.
ថ្ងៃទី...... ខែ..... ឆ្នាំ........
រដ្ឋទេយ្យករបុរេប្រទាន

**ឧបសម្ព័ន្ធទី ២**

(ឧបសម្ព័ន្ធភ្ជាប់លិខិតលេខ............ សហវ.......... ចុះថ្ងៃទី.......... ខែ.......... ឆ្នាំ ២០២៣ ស្តីពីគោលការណ៍នៃការអនុវត្តចំណាយថវិកាសម្រាប់គាំទ្រដល់ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ)

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**

**មន្ទីរអប់រំ យុវជន និងកីឡារាជធានី/ខេត្ត..........**

**គម្រោងចំណាយថវិកាសម្រាប់គាំទ្រដល់ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ ប្រចាំឆ្នាំ..........**

**របស់មន្ទីរអប់រំ យុវជន និងកីឡារាជធានី/ខេត្ត............**

| ជំពូក | គណនី | អនុគណនី | បរិយាយ | ឥណទានថវិកាបើកផ្តល់សាច់ប្រាក់មុន | ឥណទានថវិកាបើកផ្តល់សាច់ប្រាក់មុនលើកដំបូង |
|---|---|---|---|---|---|
| | | | | ១ | ២=១* ៥០% |
| | | សរុប | | | |
| កម្មវិធីទី.....អនុកម្មវិធីទី....... ចង្កោមសកម្មភាពទី........ សកម្មភាពទី..... | | | | | |
| ៦២ | ៦២០២ | ៦២០២៨ | ជំនួយសង្គមផ្សេងៗទៀត | | |

បានឃើញនិងឯកភាព
ថ្ងៃ...ខែ....ឆ្នាំ.....ព.ស.
ថ្ងៃទី...ខែ.....ឆ្នាំ.....
ប្រធានមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត....

បានឃើញនិងពិនិត្យត្រឹមត្រូវ
ថ្ងៃ...ខែ....ឆ្នាំ.....ព.ស.
ថ្ងៃទី...ខែ.....ឆ្នាំ.....
ប្រធានការិយាល័យ........ហិរញ្ញវត្ថុ

ថ្ងៃ..............ខែ............ឆ្នាំ.........ព.ស........
..........,ថ្ងៃទី..........ខែ..........ឆ្នាំ..........
រដ្ឋលេខាធិការ

## ឧបសម្ព័ន្ធទី ៣

(ឧបសម្ព័ន្ធភ្ជាប់លិខិតលេខ............ សហវ.......... ចុះថ្ងៃទី........... ខែ.......... ឆ្នាំ ២០២៣ ស្តីពីគោលការណ៍នៃការអនុវត្តចំណាយថវិកាសម្រាប់គាំទ្រដល់ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ)

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**
**មន្ទីរអប់រំ យុវជន និងកីឡារាជធានី/ខេត្ត..........**

**របាយការណ៍ចំណាយរបស់មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត..........**
**សម្រាប់ចំណាយប្រាក់បេសកកម្មក្នុងប្រទេសជូនការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ ចាប់ពីថ្ងៃទី.....ខែ.......ឆ្នាំ.....ដល់ថ្ងៃទី.....ខែ.....ឆ្នាំ...**
**កម្មវិធីទី....អនុកម្មវិធីទី....ចង្កោមសកម្មភាពទី....សកម្មភាពទី.....**

| ល.រ | គោត្តនាម នាម | តួនាទី | ប្រភេទមុខតំណែង | លិខិតបេសកកម្ម | | កម្មវត្ថុនៃការចុះបេសកកម្ម | ទីកន្លែង | កាលបរិច្ឆេទចុះបេសកកម្ម | | ចំនួនថ្ងៃ | ចំនួនយប់ | សោហ៊ុយធ្វើដំណើរ | ប្រាក់ហោប៉ៅ | | ប្រាក់ហូបចុក | | ប្រាក់ស្នាក់នៅ | | សោហ៊ុយផ្សេងៗ | ទឹកប្រាក់សរុប |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | លេខ | កាលបរិច្ឆេទ | | | ចាប់ផ្តើម | ត្រលប់ | | | | របប | សរុប | របប | សរុប | របប | សរុប | | |
| | | | | | | | | | | ១ | ២ | ៣ | ៤ | ៥=១X៤ | ៦ | ៧=១X៦ | ៨ | ៩=១X៨ | ១០ | ១១=៣+៥+៧+៩+១០ |
| សរុបរួម | | | | | | | | | | | | | | | | | | | | |
| ១.ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ........... | | | | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | | | |
| ២.ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ........... | | | | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | | | |

ចំនួនទឹកប្រាក់សរុប÷................................(ជាអក្សរ÷...........................................)។

| បានឃើញនិងឯកភាព | បានឃើញនិងពិនិត្យត្រឹមត្រូវ | ថ្ងៃ............... ខែ............. ឆ្នាំ......... ព.ស........ |
|---|---|---|
| ថ្ងៃ...ខែ....ឆ្នាំ.....ព.ស. | ថ្ងៃ...ខែ....ឆ្នាំ.....ព.ស. | ..........,ថ្ងៃទី.......... ខែ.......... ឆ្នាំ.......... |
| ថ្ងៃទី...ខែ.....ឆ្នាំ..... | ថ្ងៃទី...ខែ.....ឆ្នាំ..... | រដ្ឋលេខាធិការប្រធានប្រទាន |
| ប្រធានមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត.... | ប្រធានការិយាល័យ........ហិរញ្ញវត្ថុ | |

## ឧបសម្ព័ន្ធទី ៤

(ឧបសម្ព័ន្ធភ្ជាប់លិខិតលេខ............ សហវ.......... ចុះថ្ងៃទី........... ខែ.......... ឆ្នាំ ២០២៣ ស្តីពីគោលការណ៍នៃការអនុវត្តចំណាយថវិកាសម្រាប់គាំទ្រដល់ ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ)

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**
**មន្ទីរអប់រំ យុវជន និងកីឡារាជធានី/ខេត្ត..........**

### របាយការណ៍ចំណាយរបស់មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត.............
### លើសម្ភារសម្រាប់ការងាររដ្ឋបាលរបស់ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ
### កម្មវិធីទី....អនុកម្មវិធីទី.....ចង្កោមសកម្មភាពទី.....សកម្មភាពទី......

| ល.រ | បណ្ណចំណាយ | | ថ្ងៃ ខែ ឆ្នាំ វិក្កយបត្រ ឬ សក្ខីបត្រចំណាយ | មាតិកាថវិកា | | | បរិយាយ | ទឹកប្រាក់ |
|---|---|---|---|---|---|---|---|---|
| | លេខ | ថ្ងៃ ខែ ឆ្នាំ | | ជំពូក | គណនី | អនុគណនី | | |
| **សរុបរួម** | | | | | | | | .......... |
| | | | | ៦២ | ៦២០២ | ៦២០២៨ | ជំនួយសង្គមផ្សេងៗទៀត | .......... |
| ១. ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ......... | | | | | | | | |
| | | | | ៦២ | ៦២០២ | ៦២០២៨ | ជំនួយសង្គមផ្សេងៗទៀត | .......... |
| .... | ....... | ................ | ........... | | | | ................. | .......... |
| ២. ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ.......... | | | | | | | | |
| | | | | ៦២ | ៦២០២ | ៦២០២៨ | ជំនួយសង្គមផ្សេងៗទៀត | .......... |
| .... | ....... | ................ | ........... | | | | ................. | .......... |

ចំនួនទឹកប្រាក់សរុប÷...............................(ជាអក្សរ÷.........................................)។

បានឃើញនិងឯកភាព
ថ្ងៃ...ខែ....ឆ្នាំ.....ព.ស.
ថ្ងៃទី...ខែ.....ឆ្នាំ.....
ប្រធានមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត....

បានឃើញនិងពិនិត្យត្រឹមត្រូវ
ថ្ងៃ...ខែ....ឆ្នាំ.....ព.ស.
ថ្ងៃទី...ខែ.....ឆ្នាំ.....
ប្រធានការិយាល័យ........ហិរញ្ញវត្ថុ

ថ្ងៃ..............ខែ............ឆ្នាំ.........ព.ស........
..........,ថ្ងៃទី..........ខែ..........ឆ្នាំ..........
រដ្ឋលេខាធិការបុរេប្រទាន